**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្តបាត់ដំបង**
**រដ្ឋបាលស្រុកបាណន់**
លេខ៖.ᨐ០១/២០...ដក.សបណ

# ដីកា
## ស្ដីពីការកំណត់តម្លៃសេវា និង
## ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន របស់រដ្ឋបាលស្រុកបាណន់

### ក្រុមប្រឹក្សាស្រុកបាណន់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស.រកម.១២៩៦.៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រម នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រម នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រម នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្ដីពីនីតិវិធីសម្រាប់ការរៀបចំការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ៥៧៩ អនក្រ.តត ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩ ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាស្រុកបាណន់ នៃខេត្តបាត់ដំបង
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន
- បានឃើញប្រកាសអន្តរក្រសួងលេខ១៩៥ ប្រក.ប.ស្ក ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០១៨ ស្ដីពីការកំណត់តម្លៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

- បានឃើញប្រកាសអន្តរក្រសួងលេខ ៨៦៨២ ប្រក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍ ចំពោះអំពើល្មើសនឹងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

យោងស្មារតីកិច្ចប្រជុំវិសាមញ្ញ អាណត្តិទី៣ របស់ក្រុមប្រឹក្សាស្រុកបាណន់ នាថ្ងៃទី ....ខែ ....ឆ្នាំ ២០២០ ស្តីពីការពិភាក្សាលើការកំណត់តម្លៃសេវា និងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនស្រុកបាណន់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ដីកានេះមានគោលបំណងកំណត់អំពីតម្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ផ្អែកតាមប្រភេទអាជីវកម្ម ទីតាំង បរិមាណសំរាមដែលត្រូវបញ្ចេញ និងកម្រិតប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ ព្រមទាំងធ្វើឱ្យមានភាពប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងស្រុកបាណន់ ប្រកបដោយប្រសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងនិរន្តរភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាពសាធារណៈ និងបរិស្ថាន។

**ប្រការ២._**

**ដីកានេះមានគោលដៅដូចតទៅ៖**

- កំណត់អំពីតម្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅក្នុងស្រុកបាណន់
- កំណត់វិធានការចាំបាច់ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ពង្រឹងការអនុវត្តតួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់រដ្ឋបាលស្រុក ក្រុមហ៊ុន ឬអ្នកម៉ៅការ និងប្រជាពលរដ្ឋ ព្រមទាំងអ្នកពាក់ព័ន្ធនានាលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ ការអនុវត្តវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- លើកកម្ពស់សុខមាលភាពរស់នៅឱ្យកាន់តែប្រសើរឡើង តាមរយៈការសម្អាតអនាម័យបរិស្ថាន
- ធ្វើឱ្យស្រុកបាណន់មានសណ្តាប់ធ្នាប់អនាម័យ ក្លាយជាស្រុកមានសោភ័ណភាពបៃតង
- ធានាការប្រមូលតម្លៃសេវា និងការផ្តល់សេវាសម្អាត ប្រមូល ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនឱ្យកាន់តែមានភាពច្បាស់លាស់ មានតម្លាភាព និងគណនេយ្យភាព។

**ប្រការ៣._**

ដីកានេះមានវិសាលភាពសម្រាប់ការអនុវត្តសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ព្រមទាំងអនុវត្តលើការញែក ការទុកដាក់ ការសម្អាត ការប្រមូល ការដឹកជញ្ជូន ការកែច្នៃ និងការគ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងដែនសមត្ថកិច្ចរដ្ឋបាលស្រុកបាណន់ ។

ដីកានេះ ពុំមានវិសាលភាពអនុវត្តលើការងារគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម និងសំណល់គ្រោះថ្នាក់ឡើយ។

**ប្រការ៤._**

វាក្យសព្ទដែលប្រើក្នុងដីកានេះ ត្រូវបានកំណត់និយមន័យដូចមានចែងក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១ នៃដីកានេះ។

បញ្ជីសំណល់គ្រោះថ្នាក់ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍មានកំណត់ក្នុងឧបសម្ព័ន្ធទី២ នៃដីកានេះ។

## ជំពូកទី២
## កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ស្រុកបាណន់

**ប្រការ៥._**

កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នៅក្នុងរដ្ឋបាលស្រុកបាណន់ ជាកម្រៃដែលរាប់បញ្ចូលនូវកម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

**ប្រការ៦._**

កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនត្រូវបានកំណត់ដូចមានចែងនៅក្នុងតារាងជាឧបសម្ព័ន្ធទី៣ នៃដីកានេះ។

កម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនអាចត្រូវយកកម្រៃទាបជាងកម្រៃដែលបានកំណត់ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ តាមរយៈការចរចារ ក្នុងករណីដែលម្ចាស់សំរាមបានធ្វើការញែក វេចខ្ចប់ ទុកដាក់សំរាម សំណល់រឹងបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

## ជំពូកទី៣
## តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋបាលស្រុក ប្រជាពលរដ្ឋ និងក្រុមហ៊ុនលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**ប្រការ៧._**

**រដ្ឋបាលស្រុកបាណន់មានតួនាទី ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖**

- រៀបចំផែនការគ្រប់គ្រង ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ដាក់ចេញ និងផ្សព្វផ្សាយដីកា ឬលិខិតបទដ្ឋាននានា ស្តីពីការកំណត់កម្រៃសេវា និងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ ដើម្បីជានាឱ្យមានការចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវ
- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជន
- ណែនាំដល់ប្រជាពលរដ្ឋអំពីការសម្អាតអនាម័យបរិស្ថាន ការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ចេញសំរាម សំណល់រឹង និងការប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

- អប់រំ និងផ្សព្វផ្សាយអំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយសុវត្ថិភាពបរិស្ថានអំពីកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ( 3R: Reduce, Reuse, Recycle) និងអំពីការលើកកម្ពស់ការប្រើប្រាស់ផលិតផលដែលបានមកពីការកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- ចុះកិច្ចសន្យាសម្អាត ប្រមូល ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនជាមួយក្រុមហ៊ុនឯកជន សហគមន៍ និងដៃគូផ្សេងៗទៀត
- ចាត់វិធានការត្រួតពិនិត្យលើការអនុវត្តការបញ្ចេញកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់
- តាមដាន ត្រួតពិនិត្យ វាយតម្លៃការប្រមូលកម្រៃសេវា និងការអនុវត្តសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមពីតាមទីតាំងបង្កើតសំរាម
- កំណត់ទីតាំងស្តុកទុកសំរាមបណ្តោះអាសន្ន ដែលមានលក្ខណៈសមស្រប
- សម្របសម្រួល និងផ្តល់លក្ខខណ្ឌពិសេសក្នុងការប្រមូលកម្រៃសេវាសម្អាត ប្រមូល ដឹកជញ្ជូនសំរាមសម្រាប់សហគមន៍ និងប្រជាពលរដ្ឋក្រីក្រដែលមានកម្រិតចំណូលទាបនៅក្នុងស្រុក
- ពិនិត្យលទ្ធភាពបង្កើតសហគមន៍គ្រប់គ្រងសំរាមស្វយ័ត ដែលទទួលខុសត្រូវគ្រប់គ្រងសំរាម និងប្រមូលកម្រៃសេវាដោយផ្ទាល់នៅក្នុងសហគមន៍
- ដោះស្រាយរាល់បញ្ហាប្រឈមនានាក្នុងការផ្តល់សេវាសម្អាត ប្រមូល ដឹកជញ្ជូនសំរាម និងការខកខានបង់ថ្លៃសេវាសំរាម
- ចាត់ចែងឱ្យមានធុងសំរាមនៅតាមទីកន្លែងសាធារណៈ
- អាចធ្វើប្រតិភូកម្មមុខងារមួយផ្នែកក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលឃុំ

**ប្រការ៨._**

ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ដែលបានកំណត់ដោយរដ្ឋបាលស្រុកបាណន់ ដូចមានចែងក្នុងប្រការ៦ នៃដីកានេះ។

**ប្រការ៩._**

**ម្ចាស់សំរាម សំណល់រឹងទីប្រជុំជនដែលមានទីតាំងស្ថិតក្នុងស្រុកបាណន់ មានតួនាទី ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖**

- ធ្វើការញែក និងវេចខ្ចប់សំរាម សំណល់រឹងដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបានដាច់ដោយឡែកពីសំរាម សំណល់រឹងដែលត្រូវបោះចោល
- ត្រូវវេចខ្ចប់សំរាម សំណល់រឹងទីប្រជុំជនដោយថង់ ឬដាក់ក្នុងធុងសំរាមផ្ទាល់ខ្លួន ក្នុងលក្ខណៈហ្មត់ចត់មិនឲ្យលេចធ្លាយ មិនឲ្យលេចជ្រាបទឹកស្អុយ ឬភាយក្លិនស្អុយ
- រក្សាទុកនូវកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬបរិវេណនៃលំនៅឋាន អគារ ឬទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលស្រុក ឬភ្នាក់ងារមាន សមត្ថកិច្ច
- សម្អាតនៅជុំវិញលំនៅឋាន អគារ និងបរិវេណទីតាំងអាជីវកម្មរបស់ខ្លួន។

**ប្រការ១០._**

ក្រុមហ៊ុន ឬអ្នកម៉ៅការ សហគមន៍ស្វយ័ត ដែលទទួលបានសិទ្ធិផ្តល់សេវាសម្អាត ប្រមូល ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម៖

- ចុះកិច្ចសន្យាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ជាមួយរដ្ឋបាលស្រុកបាណន់
- អនុវត្តតាមផែនការគ្រប់គ្រង ផែនការសកម្មភាព កាលវិភាគ ផែនទី ក្នុងការសម្អាត ប្រមូល ដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជន ដែលរដ្ឋបាលស្រុកបាណន់ បានកំណត់
- ត្រូវមានមធ្យោបាយដឹកជញ្ជូនសមស្រប កម្មករគ្រប់គ្រាន់សម្រាប់សម្អាត ប្រមូល និងដឹកជញ្ជូនសំរាម
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនរដ្ឋបាលស្រុក។

## ជំពូកទី៤
## វិធានការទូទៅលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**ប្រការ១១._**

ត្រូវបានហាមឃាត់ជាដាច់ខាតនូវការបោះចោល ឬការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល តាមប្រព័ន្ធទឹកលូ ឬប្រភពទឹកសាធារណៈ ឬក្នុងដីកម្មសិទ្ធិឯកជន។

**ប្រការ១២._**

រូបវន្តបុគ្គល និងនីតិបុគ្គល ដែលប្រើប្រាស់ទីសាធារណៈសម្រាប់ការប្រារព្ធ ឬដំណើរការកម្មវិធីរបស់ខ្លួន ត្រូវទទួលខុសត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនដែលបានបង្កើតក្នុងពិធី ទៅឱ្យអ្នកផ្តល់សេវាប្រមូលក្នុងមូលដ្ឋានទៅតាមតម្លៃដែលបានកំណត់ដោយរដ្ឋបាលស្រុក ដូចមានចែងនៅក្នុងប្រការ៦ នៃដីកានេះ។

**ប្រការ១៣._**

ម្ចាស់ ឬអ្នកគ្រប់គ្រងផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម មណ្ឌលកំសាន្ត ត្រូវរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំងសេវាកម្ម ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជន របស់អតិថិជន ឬបុគ្គលិករបស់ខ្លួន។

**ប្រការ១៤._**

ម្ចាស់កម្មសិទ្ធិ ឬអ្នកម៉ៅការការដ្ឋានវាយកម្ទេច ជួសជុល ឬសាងសង់លំនៅឋាន ឬអគារត្រូវទទួលខុសត្រូវលើសំរាម សំណល់រឹងដែលចេញពីការដ្ឋានរបស់ខ្លួន ដូចខាងក្រោម៖

- ទុកដាក់ឱ្យបានត្រឹមត្រូវ មិនបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាន
- សម្អាត ប្រមូល និងដឹកជញ្ជូនដោយខ្លួនឯងទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ឬប្រើប្រាស់ សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានក្នុង មូលដ្ឋាន និងត្រូវបង់ថ្លៃសេវាតាមការកំណត់ដោយរដ្ឋបាលស្រុកបាណន់ ដូចមានចែងក្នុងប្រការ ៦ នៃដីកានេះ។

**ប្រការ១៥._**

ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងនានា និងបុរីលំនៅឋាន ត្រូវរៀបចំកន្លែងសមស្របសម្រាប់ទុកដាក់សំរាម សំណល់រឹងទីប្រជុំជននៅក្នុងបរិវេណនៃការគ្រប់គ្រងរបស់ខ្លួន រង់ចាំការដឹកចេញដែលមិនបង្កផលប៉ះពាល់ដល់សោភ័ណភាព សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសុខភាពសាធារណៈ។

**ប្រការ១៦.-**

ការធ្វើអាជីវកម្មបូម ដឹកជញ្ជូន និងការបោះចោលសំណល់កកពីអាងស៊ីបទិក ត្រូវមានការអនុញ្ញាតពីរដ្ឋបាលស្រុក បន្ទាប់ពីបានទទួលយោបល់បច្ចេកទេសពីមន្ទីរបរិស្ថានខេត្ត។

## ជំពូកទី៥

## ទោសប្បញ្ញត្តិ

**ប្រការ១៧.-**

បុគ្គលដែលបានប្រើប្រាស់សេវាសម្អាត ប្រមូល ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ហើយមិនព្រមបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ដែលកំណត់ដោយរដ្ឋបាលស្រុកបាណន់ ដូចមានចែងក្នុងប្រការ៨ នៃដីការនេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃតម្លៃសេវាសំរាម សំណល់រឹងដែលត្រូវបង់ក្នុងមួយខែ។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**ប្រការ១៨.-**

ក្រុមហ៊ុន ឬអ្នកម៉ៅការ សហគមន៍ស្វយ័ត ដែលទទួលបានសិទ្ធិផ្តល់សេវាសម្អាត ប្រមូល ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនអនុវត្តមិនស្របតាមស្មារតីនៃដីកានេះ ត្រូវទទួលខុសត្រូវចំពោះកិច្ចសន្យាដែលបានធ្វើជាមួយរដ្ឋបាលស្រុក និងផ្លូវច្បាប់ជាធរមាន។

**ប្រការ១៩.-**

ការមិនអនុវត្តតាមការកំណត់របស់រដ្ឋបាលស្រុកក្នុងការញែក និងការវេចខ្ចប់ដោយឡែកនូវសំរាមសំណល់រឹងទីប្រជុំជនដែលអាចប្រើប្រាស់ឡើងវិញ ឬកែច្នៃបាន ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ១០.០០០ (មួយម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១០០.០០០ (មួយសែន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ២០០.០០០ (ពីរសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**ប្រការ២០.-**

បុគ្គលដែលនាំយកកញ្ចប់ ឬធុងផ្ទុកសំរាម សំណល់រឹងទីប្រជុំជន ទៅដាក់នៅតាមដងផ្លូវ ឬទីសាធារណៈខុសពេលម៉ោងអនុញ្ញាតឱ្យធ្វើការបញ្ចេញ ដែលកំណត់ដោយរដ្ឋបាលស្រុក ឬភ្នាក់ងារមានសមត្ថកិច្ច ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល សម្រាប់លំនៅឋាន
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល សម្រាប់ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ទីតាំងសិប្បកម្ម អគារខុនដូ អាប៉ាតឺម៉ែន និងបុរីលំនៅឋាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**ប្រការ២១._**

បុគ្គលដែលបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលស្រុកហាមឃាត់ការបោះចោលសំរាម សំណល់រឹងទីប្រជុំជន ដូចមានចែងក្នុងប្រការ១១ នៃដីកានេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្មដូចខាងក្រោម៖

- ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូល សំអាតយកទៅដាក់ធុងសំរាមសាធារណៈ
- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ១៥០.០០០ (មួយសែនប្រាំម៉ឺន) រៀល ចំពោះអ្នកលក់ដូរតាមផ្ទះ ភោជនីយដ្ឋាន ទីកំសាន្ត និងត្រូវប្រមូលវេចខ្ចប់យកទៅដាក់នៅទីតាំងដែលអាជ្ញាធរបានកំណត់
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**ប្រការ២២._**

បុគ្គលដែលដុតសំរាម សំណល់រឹងទីប្រជុំជននៅលើទីសាធារណៈ តាមដងផ្លូវ ទីវាល ដីកម្មសិទ្ធិ ឬទីកន្លែងដែលរដ្ឋបាលស្រុកហាមឃាត់ ដូចមានចែងក្នុងប្រការ១១ នៃដីកានេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្មដូចខាងក្រោម៖

- ចំនួន ៥០.០០០ (ប្រាំម៉ឺន) រៀល ចំពោះអ្នកដំណើរ អ្នកទេសចរណ៍ និងត្រូវប្រមូលសំអាត
- ចំនួន ១០០.០០០ (មួយសែន) រៀល ចំពោះម្ចាស់លំនៅឋាន អ្នកលក់ដូរតាមដងផ្លូវ ឬលើទីសាធារណៈ និងត្រូវប្រមូលសម្អាត
- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះទីផ្សារ ភោជនីយដ្ឋាន ទីកំសាន្ត អាជីវកម្ម សេវាកម្ម សិប្បកម្ម និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះរោងចក្រ សហគ្រាស ក្រុមហ៊ុន និងត្រូវទទួលខុសត្រូវលើការប្រមូល សំអាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**ប្រការ២៣._**

បុគ្គលដែលគេចវេសមិនទទួលខុសត្រូវលើសំរាម សំណល់រឹងទីប្រជុំជនដែលបង្កើតនៅក្នុងពិធីនានារបស់ខ្លួនដែលប្រារព្ធនៅលើដងផ្លូវ ឬនៅលើទីសាធារណៈ ដូចមានចែងក្នុងប្រការ១២ នៃដីកានេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់បន្ថែមទៅលើតម្លៃសេវាសម្អាត ប្រមូល និងដឹកជញ្ជូនដូចខាងក្រោម៖

- ចំនួន ២០០.០០០ (ពីរសែន) រៀល ចំពោះពិធីមង្គលការ សម្ពោធហាង និងបុណ្យ លើកលែងបុណ្យសព
- ចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ចំពោះពិធីប្រជុំ មិទ្ទិញ

- ចំនួន ២.០០០.០០០(ពីរលាន) រៀល ចំពោះការប្រគុំតន្ត្រីសាធារណៈ

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**ប្រការ២៤._**

បុគ្គលម្ចាស់ ឬអ្នកគ្រប់គ្រងទីផ្សារ ទីតាំងអាជីវកម្ម ទីតាំងសេវាកម្ម ក្រុមហ៊ុន រោងចក្រ សហគ្រាសសិប្បកម្ម មណ្ឌលកំសាន្ត ដែលមិនបានរៀបចំឱ្យមានធុងសំរាមនៅក្នុងទីតាំង ឬទីបរិវេណសម្រាប់ការចោលសំរាម សំណល់រឹងទីប្រជុំជនរបស់អតិថិជន ឬបុគ្គលិករបស់ខ្លួន ដូចមានចែងក្នុងប្រការ១៣ នៃដីកានេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៤០០.០០០ (បួនសែន) រៀល។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**ប្រការ២៥._**

បុគ្គលម្ចាស់ការដ្ឋានសំណង់អគារដែលធ្វើការទុកដាក់សំរាម សំណល់រឹងទីប្រជុំជនពីការងារសំណង់ ឬសម្ភារៈសំណង់មិនបានត្រឹមត្រូវតាមការកំណត់របស់រដ្ឋបាលស្រុក ឬការទុកដាក់បង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សោភ័ណភាព ឬបរិស្ថាន ដូចមានចែងក្នុងប្រការ១៤ នៃដីកានេះ ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ និងទណ្ឌកម្មដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះការដ្ឋានសំណង់លំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សម្អាត និងដឹកចេញយកទៅទីលាន
- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល ចំពោះការដ្ឋានសំណង់អគារធំៗ បុរីលំនៅឋាន និងត្រូវទទួលខុសត្រូវលើការប្រមូល សម្អាត និងដឹកចេញយកទៅទីលាន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**ប្រការ២៦._**

បុគ្គលដែលធ្វើអាជីវកម្មបូមសំណល់កក់ពីប្រព័ន្ធលូ ឬពីអាងសិុបទិកដោយមិនមានលិខិតអនុញ្ញាតពីរដ្ឋបាលស្រុក ឬដឹកយកទៅបញ្ចេញចោលខុសទីកន្លែងដែលអាជ្ញាធរមានសមត្ថកិច្ចបានកំណត់ ដូចមានចែងក្នុងប្រការ១៦ នៃដីកានេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៤០០.០០០ (បួនសែន) រៀល ចំពោះអាជីវកម្មជាលក្ខណៈគ្រួសារ
- ចំនួន ១.០០០.០០០ (មួយលាន) រៀល ចំពោះអាជីវកម្មជាលក្ខណៈក្រុមហ៊ុន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**ប្រការ២៧._**

បុគ្គលដែលធ្វើការទុកដាក់ វេចខ្ចប់ ឬប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនលាយឡំជាមួយសំណល់រឹងឧស្សាហកម្ម សំណល់វេជ្ជសាស្ត្រ ឬសំណល់គ្រោះថ្នាក់ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដូចខាងក្រោម៖

- ចំនួន ៥០០.០០០ (ប្រាំសែន) រៀល សម្រាប់អាជីវកម្ម សិប្បកម្ម មន្ទីរពេទ្យ សម្ភព

- ចំនួន ៨០០.០០០ (ប្រាំបីសែន) រៀល សម្រាប់រោងចក្រ សហគ្រាស ក្រុមហ៊ុន
- ចំនួន ១.០០០.០០០ (មួយលាន) រៀល សម្រាប់ក្រុមហ៊ុនសេវាប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងករណីមិនរាងចាល ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍លើកមុន។

**ប្រការ២៨._**

បុគ្គលដែលមិនបានបង់ប្រាក់ពិន័យអន្តរការណ៍នេះក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃដែលបានទទួលបង្កាន់ដៃបង់ប្រាក់ពិន័យ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាពីរដង បើលើសពី៦០(ហុកសិប)ថ្ងៃ ចំនួនប្រាក់ពិន័យនេះនឹងត្រូវដំឡើងជាបីដង។ បើផុតរយៈពេល៩០(កៅសិប)ថ្ងៃ រដ្ឋបាលស្រុកនឹងរៀបចំសំណុំឯកសារប្ដឹងទៅសាលាដំបូងខេត្ត។

**ប្រការ២៩._**

បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចផាកពិន័យអន្តរការណ៍របស់មន្ត្រីមានសមត្ថកិច្ចរបស់ស្រុក មានសិទ្ធិប្ដឹងតវ៉ាទៅអភិបាលស្រុក។

អភិបាលស្រុកសម្រេចលើបណ្ដឹងតវ៉ាក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យបណ្ដឹង។

បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់ស្រុក មានសិទ្ធិប្ដឹងទៅតុលាការតាមនីតិវិធីជាធរមាន។

**ប្រការ៣០._**

រដ្ឋបាលស្រុក ត្រូវរៀបចំក្រុមការងារទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍ចំពោះអំពើល្មើសនានាដែលមានចែងក្នុងជំពូកទី៥ នៃដីកានេះ។

ក្រុមការងារទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍ស្រុក មានតួនាទីដឹកនាំ គ្រប់គ្រង និងអនុវត្តការពិន័យអន្តរការណ៍នៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលស្រុករបស់ខ្លួន។

ក្រុមការងារទទួលបន្ទុកអនុវត្តការពិន័យអន្តរការណ៍ស្រុក ត្រូវមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - អភិបាលស្រុក | ប្រធាន |
| - តំណាងមន្ទីរបរិស្ថាន | សមាជិក |
| - តំណាងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាងអធិការដ្ឋាននគរបាលស្រុក | សមាជិក |
| - មេឃុំទាំងអស់ | សមាជិក |
| - នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំទាំងអស់ | សមាជិក |
| - មន្ត្រីរដ្ឋបាលស្រុកទទួលបន្ទុកការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | សមាជិក |

ក្រុមការងារនេះ អាចបន្ថែមសមាសភាពអ្នកពាក់ព័ន្ធមួយចំនួនជាសមាជិកតាមការចាំបាច់។

ការបង្កើតក្រុមការងារនេះ ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលស្រុក។

ក្រុមការងារនេះ អាចរៀបចំឱ្យមានភ្នាក់ងារអនុវត្តការពិន័យអន្តរការណ៍ តាមគោលដៅនីមួយៗតាមការចាំបាច់។ ការរៀបចំភ្នាក់ងារនេះ ត្រូវធ្វើឡើងដោយសេចក្ដីសម្រេចរបស់រដ្ឋបាលស្រុក។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ៣១._**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងដីកានេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៣២._**

គណៈអភិបាលស្រុក នាយករដ្ឋបាលសាលាស្រុក ប្រធានការិយាល័យ អង្គភាពចំណុះឱ្យរដ្ឋបាលស្រុក រដ្ឋបាលឃុំទាំង៨ក្នុងស្រុកបាណន់ ប្រតិបត្តិករទទួលបានសិទ្ធិផ្តល់សេវាសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា ស្ថិតនៅក្នុងដែនសមត្ថកិច្ចរដ្ឋបាលស្រុកបាណន់ ត្រូវទទួលបន្ទុកអនុវត្តដីកានេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ២ រោច....ខែ..ពិស្ស....ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅបាណន់, ថ្ងៃទី..៣១....ខែ...ធ្នូ......ឆ្នាំ២០២០

**ក្រុមប្រឹក្សាស្រុកបាណន់**

**ប្រធាន**

**ជុំ ញ៉ូ**

**<u>កន្លែងទទួល៖</u>**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- លេខាធិការដ្ឋាន គ.ជ.អ.ប
- រដ្ឋបាលខេត្តបាត់ដំបង
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
- មន្ទីរបរិស្ថានខេត្ត
- រដ្ឋបាលឃុំទាំង៨
- ដូចប្រការ៣២
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## សទ្ទានុក្រម

**១- សំរាម** សំដៅដល់របស់របរប្រើប្រាស់ សម្ភារ ផលិតផលដែលបានបន្សល់ ឬបង្កើតពីសកម្មភាព និងជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ ដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់

**២. សំណល់រឹងទីប្រជុំជន** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាពអាជីវកម្ម ឬសេវាកម្មដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

**៣. សំណល់រឹងឧស្សាហកម្ម** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាពផលិតកម្មនៃរោងចក្រ ឬសហគ្រាសដែលមិនមានផ្ទុកសារធាតុពុល ឬសំណល់គ្រោះថ្នាក់។

**៤. សំណល់គ្រោះថ្នាក់** សំដៅដល់វត្ថុធាតុរឹង រាវ ឧស្ម័ន សារធាតុវិទ្យុសកម្ម សារធាតុផ្ទុះ សារធាតុឆេះ សារធាតុចម្លងជម្ងឺ ឬធ្វើឱ្យលោក ធ្វើឱ្យច្រេះ ធ្វើអុកស៊ីតកម្ម បង្កការពុល បង្កឱ្យមានជម្ងឺមហារីក ឬសារធាតុគីមីពុលដទៃទៀតដែលបង្កឱ្យមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន។ ប្រភពសំណល់គ្រោះថ្នាក់អាចមានប្រភពមកពីលំនៅឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកំសាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្ម សេវាកម្ម សិប្បកម្ម រោងចក្រ សកម្មភាពកសិកម្ម និងអាជីវកម្មរ៉ែ។

**៥. ការទាញយកធនធាន** សំដៅដល់សកម្មភាពជម្រើស ឬប្រើប្រាស់សំរាម សំណល់រឹងធ្វើជាជីកំប៉ុស្ត៍ កែច្នៃ ទាញយកថាមពល ឬសារប្រយោជន៍នានា។

**៦. ការកែច្នៃ** សំដៅដល់សកម្មភាព ឬដំណើរការបំបែក ឬបំលែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

**៧. ការប្រើប្រាស់ឡើងវិញ** សំដៅដល់ការជម្រើសសំរាម សំណល់រឹងដែលអាចប្រើប្រាស់សារជាថ្មីឡើងវិញដោយគ្រាន់តែឆ្លងកាត់ការលាងសម្អាត ឬការជួសជុលដោយនៅរក្សាទ្រង់ទ្រាយដើម។

**៨. ការញែក** សំដៅដល់ការបែងចែកទៅតាមប្រភេទនៃសំរាម សំណល់រឹងនៅនឹងប្រភពបង្កើតសម្រាប់គោលបំណងការទាញយកធនធាន ឬដើម្បីសុវត្ថិភាពក្នុងការយកទៅចាក់នៅទីលាន។

**៩- ទីលាន** សំដៅដល់ទីកន្លែងដែលអាជ្ញាធរបានកំណត់ ឬរៀបចំតាមវិធានសុវត្ថិភាពបរិស្ថានសម្រាប់ការចាក់សំរាម សំណល់រឹងទីប្រជុំជន។

**១០- ការធ្វើប្រព្រឹត្តកម្ម** សំដៅដល់សកម្មភាព ឬវិធានការនៅក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង សំរាម សំណល់រឹងទីប្រជុំជន ដែលរួមមាន៖

ក. ការបន្ថយទំហំ ឬបរិមាណសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលានដូចជា ការដោះបំបែក ការកិនកម្ទេច ការរំលាយ ឬការដុតនៅក្នុងឡ។

ខ. ការដកយក ឬកម្ទេចចោលជាតិពុល សារធាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជម្ងឺ ដែលមាននៅក្នុងសំរាម សំណល់រឹងមុនការយកទៅចាក់នៅទីលាន។

**១១- ទីប្រជុំជន** សំដៅដល់ទីរួមក្រុង ទីរួមស្រុក ទីប្រជុំជនផ្សារ និងលំនៅឋាន រួមទាំងរមណីយដ្ឋាន មណ្ឌលកំសាន្ត តំបន់ទេសចរណ៍។

**១២- ទីតាំង** សំដៅដល់កន្លែងផលិតកម្ម អាជីវកម្ម សេវាកម្ម អគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម។

**១៣- អាងស៊ិបទិក** សំដៅដល់អាងស្តុកសំណល់បង្គន់អនាម័យបឋម។

**១៤- ពិន័យអន្តរការណ៍** សំដៅដល់ការតម្រូវជនប្រព្រឹត្តល្មើសទៅនឹងប្បញ្ញត្តិ ដែលមានចែងក្នុងដីកានេះ បង់ប្រាក់ពិន័យតាមកម្រិតទណ្ឌកម្មដែលបានប្រព្រឹត្តល្មើស។

**១៥- សេវាគ្រប់គ្រងសំរាម** សំណល់រឹងទីប្រជុំជន សំដៅដល់សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

## ឧបសម្ព័ន្ធទី២

## សំណល់គ្រោះថ្នាក់ ដែលបង្កើតនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍

សំណល់គ្រោះថ្នាក់ដែលបង្កើតឡើងនៅតាមលំនៅឋាន ស្ថាប័ន ឬអគារសាធារណៈ មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេវាកម្មទេសចរណ៍រួមមាន៖

១- សំណល់អាគុយ និងថ្មពិល ឬថ្មសាកគ្រប់ប្រភេទ។

២- សំណល់គ្រឿងបរិក្ខារអគ្គីសនី និងអេឡិចត្រូនិក។

៣- សំណល់សំបកដប ឬកំប៉ុងដែលមានប្រឡាក់សារធាតុគីមី ឬថ្នាំពុលកសិកម្ម។

៤- សំណល់សំបកកង់យានយន្តគ្រប់ប្រភេទ។

៥- សំណល់ប្រេងម៉ាស៊ីន។

៦- សំណល់ថ្នាំលាប ថ្នាំជ្រលក់ពណ៌ និងសម្ភារវេចខ្ចប់។

៧- សំណល់ទឹកខ្មៅបោះពុម្ព។

៨- សំណល់ដែលជាសមាសធាតុអាបេស្តូស។

## ឧបសម្ព័ន្ធទី៣

## តារាងស្តីពីការកំណត់តម្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និង សេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន នៅក្នុងស្រុកបាណន់

| ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់ទីប្រជុំជន | ឯកតា | កម្រៃសេវាកំណត់ដោយរដ្ឋបាលស្រុក | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | សេវាសម្អាត ប្រមូល ដឹក ជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | |
| ១ | ២ | ៣ | ៧ | ៨ | ៩=៧+៨ | |
| ក | លំនៅដ្ឋាន | | | | | |
| I | លំនៅដ្ឋានរស់នៅធម្មតា | | | | | |
| | ១. ផ្ទះល្វែងជាន់ផ្ទាល់ដី | រ/ខែ | ៦ ០០០ | ១ ០០០ | ៧ ០០០ | |
| | ២. ផ្ទះល្វែងជាន់ទី១ ឡើងទៅ | រ/ខែ | ៤ ៥០០ | ១ ០០០ | ៥ ៥០០ | |
| | ៣. ផ្ទះដីឡូត៍ធម្មតា | រ/ខែ | ៥ ៥០០ | ១ ០០០ | ៦ ៥០០ | |
| | ៤. ភូមិគ្រឹះផ្ទៃដីតូចជាង ៣០០ម$^២$ | រ/ខែ | ១៣ ០០០ | ២ ០០០ | ១៥ ០០០ | |
| | ៥. ភូមិគ្រឹះផ្ទៃដីចាប់ពី ៣០០ម$^២$-៦០០ម$^២$ | រ/ខែ | ២០ ០០០ | ៣ ០០០ | ២៣ ០០០ | |
| | ៦. ភូមិគ្រឹះផ្ទៃដីធំជាង៦០០ម$^២$ | រ/ខែ | សមាមាត្រ | | | |
| II | លំនៅដ្ឋានក្នុងបុរី/ក្រុងរណប | | | | | |
| | ១. ផ្ទះល្វែង | រ/ខែ | ៦ ០០០ | ១ ០០០ | ៧ ០០០ | |
| | ២. វីឡាភ្លោះ | រ/ខែ | ១៣ ០០០ | ១ ៥០០ | ១៤ ៥០០ | |
| | ៣. វិឡាទោល ផ្ទៃដីតូចជាង៣០០ម$^២$ | រ/ខែ | ១៧ ០០០ | ២ ០០០ | ១៩ ០០០ | |
| | ៤. វិឡាទោល ផ្ទៃដីចាប់ពី ៣០០ម$^២$ ឡើង | រ/ខែ | សមាមាត្រ | | | |
| III | ខុនដូ/អាផាតមិន(គិតចំនួនយូនីត) | | | | | |
| | ១. តូចជាង៣បន្ទប់/យូនីត | រ/យូនីត/ខែ | ១៤ ៣០០ | ១ ២០០ | ១៥ ៥០០ | |
| | ២. ចាប់ពី៣បន្ទប់/យូនីត | រ/យូនីត/ខែ | សមាមាត្រ | | | |
| IV | ផ្ទះជួលឱ្យកម្មករ(គិតចំនួបន្ទប់) | | | | | |
| | ១. ផ្ទះ/អាគារជួលឱ្យកម្មករស្នាក់នៅ | រ/បន្ទប់/ខែ | ៣ ៥០០ | ៥ ០០ | ៤ ០០០ | |
| V | ផ្ទះជួលឱ្យបរទេសស្នាក់នៅ | | | | | |
| | ១. ផ្ទះជួលឱ្យបរទេសស្នាក់នៅ | រ/ខែ | ទ្វេគុណ | | | |
| ខ | ទីតាំងអាជីវកម្មទូទៅ | | | | | |
| I | ផ្ទះធ្វើអាជីវកម្មទូទៅ | | | | | |
| | ១. ទំហំផ្ទះ១ល្វែង | រ/ខែ | ២០ ០០០ | ២ ០០០ | ២២ ០០០ | |
| | ២. ទំហំចាប់ពីផ្ទះ២ល្វែងឡើង | រ/ខែ | សមាមាត្រ | | | |
| II | ឱសថស្ថាន | | | | | |

| ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់ទីប្រជុំជន | ឯកតា | កម្រៃសេវាកំណត់ដោយរដ្ឋបាលស្រុក | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | សេវាសម្អាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | |
| ១ | ២ | ៣ | ៧ | ៨ | ៩=៧+៨ | |
| | ១. ទំហំផ្ទះ១ល្វែង | រ/ខែ | ២២ ៦០០ | ២ ៤០០ | ២៥ ០០០ | |
| | ២. ទំហំចាប់ពីផ្ទះ២ល្វែងឡើង | រ/ខែ | សមាមាត្រ | | | |
| III | ភោជនីយដ្ឋាន/អាហារដ្ឋាន | | | | | |
| | ១. អាហារដ្ឋានផ្ទះ១ល្វែង(១ជាន់) | រ/ខែ | ៣៧ ០០០ | ៣ ០០០ | ៤០ ០០០ | |
| | ២. ភោជនីយដ្ឋានផ្ទះ១ល្វែង(១ជាន់) | រ/ខែ | ៦១ ០០០ | ៦ ០០០ | ៦៧ ០០០ | |
| | ៣. ភោជនីយដ្ឋាន/អាហារដ្ឋានធំជាង១ល្វែង | រ/ខែ | សមាមាត្រ | | | |
| | ៤. ភោជនីយដ្ឋានប៊ូហ្វេ (គិតផ្ទៃអាគារ) | រ/ម$^{២}$.ខែ | ១ ៣០០ | ២ ០០ | ១ ៥០០ | |
| គ | សណ្ឋាគារ និងផ្ទះសំណាក់ | | | | | |
| I | បឹងហ្គាឡូ(គិតចំនួនបន្ទប់) | | | | | |
| | ១. បឹងហ្គាឡូ | រ/បន្ទប់/ខែ | ១៧ ០០០ | ២ ០០០ | ១៩ ០០០ | |
| II | សណ្ឋាគារ (គិតចំនួនបន្ទប់) | | | | | |
| | ១. មានអាហារដ្ឋាន | រ/បន្ទប់/ខែ | ៧ ០០០ | ១ ៥០០ | ៨ ៥០០ | |
| | ២. គ្មានអាហារដ្ឋាន | រ/បន្ទប់/ខែ | ៧ ២០០ | ៨ ០០ | ៨ ០០០ | |
| III | ផ្ទះសំណាក់(គិតចំនួនបន្ទប់) | | | | | |
| | ១. ផ្ទះសំណាក់ | រ/បន្ទប់/ខែ | ៤ ៤០០ | ៦ ០០ | ៥ ០០០ | |
| ឃ | មណ្ឌលកំសាន្ត | | | | | |
| I | រង្គសាល-ក្លឹប(គិតផ្ទៃអាគារ) | | | | | |
| | ១. ទំហំតូចជាង ២០០ម$^{២}$ | រ/ខែ | ៤៣០ ០០០ | ១៥ ០០០ | ៤៤៥ ០០០ | |
| | ២. ទំហំចាប់ពី ២០០ម$^{២}$-៤០០ម$^{២}$ | រ/ខែ | ៨០០ ០០០ | ៣៥ ០០០ | ៨៣៥ ០០០ | |
| | ៣. ទំហំធំជាង ៤០០ម$^{២}$ | រ/ម$^{២}$/ខែ | ១ ៨០០ | ២ ០០ | ២ ០០០ | |
| II | KTV(គិតចំនួនបន្ទប់) | | | | | |
| | ១. KTV | រ/បន្ទប់/ខែ | ៣៥ ០០០ | ១ ៥០០ | ៣៦ ៥០០ | |
| III | បៀរហ្គាឌិន/សាច់អាំង | | | | | |
| | ១. ចំណុះតិចជាង ១៥តុ | រ/ខែ | ១៧០ ០០០ | ៧ ០០០ | ១៨០ ០០០ | |
| | ២. ចំណុះចាប់ពី ១៥-៣០ តុ | រ/ខែ | ៣០០ ០០០ | ១០ ០០០ | ៣១០ ០០០ | |
| | ៣. ចំណុះធំជាង ៣០តុ | រ/ខែ | សមាមាត្រ | | | |
| IV | មហោស្រប/រោងភាពយន្ត | | | | | |
| | ១. ចំណុះតិចជាង ២០០នាក់ | រ/ខែ | ៣០០ ០០០ | ២០ ០០០ | ៣២០ ០០០ | |
| | ២. ចំណុះចាប់ពី ២០០-៤០០នាក់ | រ/ខែ | ៥៥០ ០០០ | ៤៥ ០០០ | ៥៩៥ ០០០ | |

| ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់ទីប្រជុំជន | ឯកតា | កម្រៃសេវាកំណត់ដោយរដ្ឋបាលស្រុក | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | សេវាសម្អាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | |
| ១ | ២ | ៣ | ៧ | ៨ | ៩=៧+៨ | |
| | ៣. ចំណុះធំជាង ៤០០នាក់ (គិតចំនួនកៅអី) | រ/កៅអី.ខែ | ១ ៨០០ | ២ ០០ | ២ ០០០ | |
| V | កាស៊ីណូ(មិនគិតបញ្ចូលភោជនីយដ្ឋាន ក្លឹបកំសាន្តផ្សេងៗ) | | | | | |
| | ១. ចំណុះតិចជាង ២០០នាក់ | រ/ខែ | ២ ៩០០ ០០០ | ៩០ ០០០ | ២ ៩៩០ ០០០ | |
| | ២. ចំណុះចាប់ពី ២០០-៤០០នាក់ | រ/ខែ | ៥ ៨០០ ០០០ | ១៩០ ០០០ | ៥ ៩៩៩ ០០០ | |
| | ៣. ចំណុះលើសពី ៤០០នាក់ឡើង | រ/ខែ | សមាមាត្រ | | | |
| ង | មជ្ឈមណ្ឌលពាណិជ្ជកម្ម/លក់ដូរ | | | | | |
| I | ផ្សារទំនើប (គិតផ្ទៃអាគារ) | | | | | |
| | ១. អាគារលក់ទំនិញ/ ផ្សារទំនើប | រ/ម²/ខែ | ១ ៥០០ | ២ ០០ | ១ ៧០០ | |
| II | ផ្សារលក់ដូរធម្មតា(គិតផ្ទៃទីតាំងលក់ដូរ) | | | | | |
| | ១. ផ្សារ | រ/ម²/ខែ | ១ ៣០០ | ២ ០០ | ១ ៥០០ | |
| III | ហាងទំនិញ(គិតផ្ទៃអាគារ) | | | | | |
| | ១. ហាងទំនិញធម្មតា | រ/ម²/ខែ | ៨ ០០០ | ២ ០០ | ១ ០០០ | |
| | ២. មីនីម៉ាត | រ/ម²/ខែ | ៨ ០០០ | ២ ០០ | ១ ០០០ | |
| IV | អាគារពាណិជ្ជកម្ម(គិតផ្ទៃអាគារ) | | | | | |
| | ១. អាគារពាណិជ្ជកម្ម | រ/ម²/ខែ | ១ ០០០ | ២ ០០ | ១ ២០០ | |
| ច | មន្ទីរពេទ្យ/សុខភាពឯកជន-ស្វយ័ត | | | | | |
| I | មន្ទីរពេទ្យ (គិតចំនួនគ្រែ) | | | | | |
| | ១. មន្ទីរពេទ្យ | រ/គ្រែ.ខែ | ៩ ០០០ | ១ ០០០ | ១០ ០០០ | |
| II | មន្ទីរសម្ភព (គិតចំនួនគ្រែ) | | | | | |
| | មន្ទីរសម្ភព | រ/គ្រែ.ខែ | ៧ ០០០ | ១ ០០០ | ៨ ០០០ | |
| III | មន្ទីរសំរាកព្យាបាលជំងឺ(គិតចំនួនគ្រែ) | | | | | |
| | ១. មន្ទីរសំរាកព្យាបាលជំងឺ | រ/គ្រែ.ខែ | ៥ ២០០ | ៨០០ | ៦ ០០០ | |
| IV | បន្ទប់ពិគ្រោះ | | | | | |
| | ១. បន្ទប់ពិគ្រោះ | រ/ខែ | ១៨ ០០០ | ២ ០០០ | ២០ ០០០ | |
| ឆ | គ្រឹះស្ថានអប់រំឯកជន-ស្វយត័/អង្គការ | | | | | |
| I | សាកល/មហាវិទ្យាល័យ | | | | | |
| | ១. តិចជាង ១០បន្ទប់ | រ/ខែ | ១៣៣ ០០០ | ១០ ០០០ | ១៤៣ ០០០ | |
| | ២. ចាប់ពី ១០-៣០ បន្ទប់ | រ/ខែ | ៤០០ ០០០ | ២៨ ៥០០ | ៤២៨ ៥០០ | |

| ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់ទីប្រជុំជន | ឯកតា | កម្រៃសេវាកំណត់ដោយរដ្ឋបាលស្រុក | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | សេវាសម្អាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | |
| ១ | ២ | ៣ | ៧ | ៨ | ៩=៧+៨ | |
| | ៣. ច្រើនជាង ៣០បន្ទប់ | រ/ខែ | សមាមាត្រ | | | |
| II | សាលារៀនចំណេះទូទៅ | | | | | |
| | ១. តិចជាង ១០បន្ទប់ | រ/ខែ | ៨៦ ០០០ | ១៤០០០ | ១០០ ០០០ | |
| | ២. ចាប់ពី ១០-៣០ បន្ទប់ | រ/ខែ | ២៤៥ ០០០ | ១៥ ៥០០ | ២៨៥ ៥០០ | |
| | ៣. ច្រើនជាង ៣០បន្ទប់ | រ/ខែ | សមាមាត្រ | | | |
| II | សាលាអង្គការមិនយកថ្លៃសិក្សា | | | | | |
| | ១. តិចជាង ១០បន្ទប់ | រ/ខែ | ៦៦ ៥០០ | ១០០០០ | ៧៦៥០០ | |
| | ២. ចាប់ពី ១០បន្ទប់ឡើង | រ/ខែ | សមាមាត្រ | | | |
| III | សាលារៀនកម្រិតអន្តរជាតិ | | | | | |
| | ១. តិចជាង ១០បន្ទប់ | រ/ខែ | ៣០០ ០០០ | ១៨ ៥០០ | ៣១៨ ៥០០ | |
| | ២. ចាប់ពី ១០-២០បន្ទប់ | រ/ខែ | ៥៨៦ ៥០០ | ២៣ ៥០០ | ៦១០ ០០០ | |
| | ៣. ច្រើនជាង ២០បន្ទប់ | រ/ខែ | សមាមាត្រ | | | |
| ជ | គ្រឹះស្ថានអប់រំវដ្ឋ | | | | | |
| I | សាលាចំណេះទូទៅ | | | | | |
| | ១. សាលាចំណេះទូទៅ | រ/ខែ | ១០២ ៥០០ | ២៧៥០០ | ១៣០ ០០០ | |
| ឈ | ក្រុមហ៊ុនឯកជន | | | | | |
| I | ក្រុមហ៊ុនឯកជនទូទៅ | | | | | |
| | ១. បុគ្គលិកតិចជាង ១៥នាក់ | រ/ខែ | ៧៨ ៥០០ | ៤០០០ | ៨២ ៥០០ | |
| | ២. បុគ្គលិកចាប់ពី ១៥-៥០នាក់ | រ/ខែ | ២៤០ ៥០០ | ១៤០០០ | ២៥៤ ៥០០ | |
| | ៣. បុគ្គលិកលើសពី៥០នាក់ | រ/ខែ | សមាមាត្រ | | | |
| II | ធនាគារ/គ្រឹស្ថានហិរញ្ញវត្ថុ/មីក្រូហិរញ្ញវត្ថុ | | | | | |
| | ១. បុគ្គលិកតិចជាង ២៥នាក់ | រ/ខែ | ១៨០ ០០០ | ១០ ០០០ | ១៩០ ០០០ | |
| | ២. បុគ្គលិកចាប់ពី ១៥-៥០នាក់ | រ/ខែ | ៤០៧ ៥០០ | ១០ ០០០ | ៤១៧ ៥០០ | |
| | ៣. បុគ្គលិកលើសពី៥០នាក់ | រ/ខែ | សមាមាត្រ | | | |
| ញ | ស្ថានីយ-ដេប៉ូប្រេងឥន្ធនៈ | | | | | |
| I | មានកន្លែងលាងរថយន្ត ឬហាងទំនិញ | រ/ខែ | ១៥០ ០០០ | ១០ ០០០ | ១៦០ ០០០ | |
| II | គ្មានកន្លែងលាងរថយន្តឬហាងទំនិញ | រ/ខែ | ៧០ ០០០ | ៣ ០០០ | ៧៣ ០០០ | |
| ដ | ទីតាំងស្តុក/ផ្ទេរ ទំនិញ | | | | | |
| VI | ឃ្លាំងស្តុកទំនិញ(គិតផ្ទៃឃ្លាំ) | | | | | |
| | ១. ទំហំតូចជាង ៣០០ម² | រ/ខែ | ៧២ ៥០០ | ៣៥០០ | ៧៦ ០០០ | |

| ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់ទីប្រជុំជន | ឯកតា | កម្រៃសេវាកំណត់ដោយរដ្ឋបាលស្រុក | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | សេវាសម្អាត ប្រមូល ដឹកជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | |
| ១ | ២ | ៣ | ៧ | ៨ | ៩=៧+៨ | |
| | ២. ទំហំចាប់ពី៣០០ដល់៦០០ម² | រ/ខែ | ១៤៣ ០០០ | ៧០០០ | ១៥០ ០០០ | |
| | ៣.ទំហំធំជាង ៦០០ម² | រ/ម²/ខែ | ២ ០០ | ២ ០០ | ៤ ០០ | |
| VII | ឃ្លាំងស្តុកប្រេងឥន្ធនៈ | | | | | |
| | ១. ពោងស្តុកតិចជាង៣ | រ/ខែ | ៤២០ ០០០ | ២០ ០០០ | ៤៤០ ០០០ | |
| | ២. ពោងស្តុកចាប់ពី ៣-៤ | រ/ខែ | ៥៤០ ០០០ | ៤០ ០០០ | ៥៨០ ០០០ | |
| | ៣. ពោងស្តុកលើសពី ៤ | រ/ខែ | សមាមាត្រ | | | |
| VIII | ចំណតរថយន្តដឹក/ផ្ទេរទំនិញ(គិតផ្ទៃដី) | | | | | |
| | ១. ទំហំតូចជាង ៥០០ម² | រ/ខែ | ១០០ ០០០ | ៤ ០០០ | ១០៤ ០០០ | |
| | ២. ទំហំចាប់ពី ៥០០-១៥០០ម² | រ/ខែ | ៣០០ ០០០ | ១២ ០០០ | ៣១២ ០០០ | |
| | ៣. ទំហំធំជាង ១៥០០ម² | រ/ម²/ខែ | ៣ ០០ | ២ ០០ | ៥ ០០ | |
| IX | អាគារ/ឃ្លាំងលក់រថយន្ត-ម៉ូតូ(គិតផ្ទៃអាគារ) | | | | | |
| | ១. ទំហំតូចជាង ២០០ម² | រ/ខែ | ៤០ ០០០ | ២ ០០០ | ៤២ ០០០ | |
| | ២. ទំហំចាប់ពី ២០០- ៤០០ម² | រ/ខែ | ៦៥ ០០០ | ៤ ០០០ | ៦៩ ០០០ | |
| | ៣. ទំហំធំជាង ៤០០ម² | រ/ម²/ខែ | ៣ ០០ | ២ ០០ | ៥ ០០ | |
| ឋ | រោងចក្រ សិប្បកម្ម | | | | | |
| I | រោងចក្រ/ឧស្សាហកម្ម | | | | | |
| | ១. បុគ្គលិក/កម្មករ ក្រោម ២៥០នាក់ | រ/ខែ | ៧០០ ០០០ | ២០ ០០០ | ៧២០ ០០០ | |
| | ២. បុគ្គលិក/កម្មករ ចាប់ពី ២៥០ - ៥០០នាក់ | រ/ខែ | ១ ២៥០ ០០០ | ៥០ ០០០ | ១ ៣០០ ០០០ | |
| | ៣. បុគ្គលិក/កម្មករ លើសពី ៥០០នាក់ | រ/ខែ | សមាមាត្រ | | | |
| II | សិប្បកម្ម/ឧស្សាហកម្មធុនស្រាល | | | | | |
| | ១. បុគ្គលិក/កម្មករ ក្រោម ៥០នាក់ | រ/ខែ | ១២៤ ០០០ | ៦ ០០០ | ១៣០ ០០០ | |
| | ២. បុគ្គលិក/កម្មករ ចាប់ពី ៥០នាក់ | រ/ខែ | សមាមាត្រ | | | |
| ឌ | ស្ថានទូត - កុងស៊ុល - អង្គការ | | | | | |
| I | ស្ថានទូត - កុងស៊ុល (គិតផ្ទៃដី) | | | | | |
| | ១. តូចជាង ១២០០ម² | រ/ខែ | | | | |
| | ២. ចាប់ពី ១២០០ម² | រ/ម²ខែ | | | | |
| II | អង្គការមិនមែនរដ្ឋាភិបាល | រ/ខែ | ១០២ ០០០ | ៨ ០០០ | ១១០ ០០០ | |
| ឍ | ស្ថាបន័ន/អង្គភាពរដ្ឋ | | | | | |
| I | ក្រសួង ស្ថាប័ន | រ/ខែ | | | | |

| ល.រ | ប្រភេទទីតាំងបង្កើតសំរាមសំណល់ទីប្រជុំជន | ឯកតា | កម្រៃសេវាកំណត់ដោយរដ្ឋបាលស្រុក | | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | សេវាសម្អាត ប្រមូល ដឹក ជញ្ជូន | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | |
| ១ | ២ | ៣ | ៧ | ៨ | ៩=៧+៨ | |
| II | មន្ទីរ អង្គភាពរដ្ឋ | រ/ខែ | ៣៥ ០០០ | ៣ ០០០ | ៣៨ ០០០ | |
| ណ | ផ្សេងៗ | | | | | |
| I | ការធ្វើកម្មវិធីនៅទីសាធារណៈ | | | | | |
| | ១. កម្មវិធីអ្នកចូលរួមតិចជាង ១០០០នាក់/ថ្ងៃ | រ/ថ្ងៃ | ២០០ ០០០ | ១០ ០០០ | ២១០ ០០០ | |
| | ២. កម្មវិធីអ្នកចូលរួមចាប់ពី ១០០០-១៥០០នាក់/ថ្ងៃ | រ/ថ្ងៃ | ៤០០ ០០០ | ១៥ ០០០ | ៤១៥ ០០០ | |
| | ៣. កម្មវិធីអ្នកចូលរួមលើសពី ១៥០០នាក់/ថ្ងៃ | រ/ថ្ងៃ | សមាមាត្រ | | | |
| | ៤. ការប្រគុំតន្ត្រីក្នុង១ថ្ងៃ | រ/ថ្ងៃ | ៨០០ ០០០ | ៣០ ០០០ | ៨៣០ ០០០ | |
| II | ការលក់ដូរចល័តតាមដងផ្លូវ(ក្នុង១ថ្ងៃ) | | | | | |
| | ១. ការលក់ដូរផ្សេងៗតាមដងផ្លូវ | រ/ថ្ងៃ | ៤ ០០ | ១ ០០ | ៥ ០០ | |
| III | ការដ្ឋានសាងសង់ផ្សេងៗ(គិតបរិមាណ) | | | | | |
| | ១. បញ្ចេញសំណល់រឹងចេញពីការដ្ឋានដោយប្រើប្រាស់ក្រុមហ៊ុនផ្តល់សេវា ប្រមូលនិងដឹកជញ្ជូន | រ/តោន | ៩១ ០០០ | ៩ ០០០ | ១០០ ០០០ | |